long beach unified school district

OFFICE OF EQUITY, ACCESS, COLLEGE & CAREER READINESS
Volunteers in Public Schools

VIPS make a difference

Parent University

# មគោលនយោបាយដាក់ពាក្យសុំធ្វើជាអ្នកស្ម័គ្រជួយកិច្ចការនៅតាមសាលារៀននៃ LBUSD

## ការបំពេញក្រដាស គឺតំរូវធ្វើក្នុងរយៈពេល បួន ឆ្នាំម្តង

*ពេលវេលារត់ការសំរាប់ក្រដាសដាក់ពាក្យសុំស្ម័គ្រជួយកិច្ចការនៅតាមសាលារៀន (VIPS) គឺនឹងប្រើប្រហែល ពីរ សប្តាហ៍ ឬ លើស ។ សូមឆ្លើយបំពេញពត៌មានត្រឹមត្រូវនៅលើក្រដាស និង ចុះហត្ថលេខាបង្ហាញផង ដើម្បីជៀសវាងការពន្យារពេល ។ សូមអរគុណចំពោះការយកចិត្តទុកដាក់ ។

សូមចំណាំ: បើមានការបង្ហាញពត៌មានអំពីទោសកំហុស ដែលធ្លាប់បានទទួល **គឺក្រដាសភស្តុតាងពីតុលាការ ដែលបញ្ជាក់ថា ទោសកំហុសនោះបានរួចរាល់ផុតទៅហើយ នឹងត្រូវតែមានភ្ជាប់មកផង** ហើយវានឹងត្រូវចំណាយពេលយូរបន្តិចសំរាប់ធ្វើការតាមដាន ។ សំរាប់សំនួរផ្សេងៗអំពីការបំពេញក្រដាសដាក់ពាក្យ គឺសូមទាក់ទងអ្នកស្រី: Sharon Lazo-Nakamoto, ដែលជាអ្នកចាត់ចែងកម្មវិធី VIPS ប្រចាំក្រសួងអប់រំ ឌីស្ទ្រីគ តាមលេខទូរស័ព្ទ (562) 997- 8307 ។

សូមឆ្លើយបំពេញក្រដាសដាក់ពាក្យ VIPS និង បង្ហាញផងអំពីក្រដាសបញ្ជាក់រោគរបេង (ស្របតាមច្បាប់) ។ សូមគឹបក្រដាសបង្ហាញលទ្ធផលអំពីរោគរបេងភ្ជាប់ជាមួយក្រដាសដាក់ពាក្យ VIPS រួមទាំងក្រដាសចម្លងប័ណ្ណ ID មានរូបថត មួយសន្លឹកផង ។

↓

យកក្រដាសដាក់ពាក្យ VIPS ដែលទើបបានបំពេញ និង ចុះហត្ថលេខានៅពីលើផង រួមទាំងយកការចម្លងលទ្ធផលអំពីរោគរបេង និង ប័ណ្ណ ID ទៅប្រគល់ជូនអ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀន ។ លទ្ធផលអំពីរោគរបេង គឺត្រូវបញ្ជាក់ ថ្ងៃ/ខែ ដែលបានធ្វើ តែស្ត ស្បែក ថ្ងៃ/ខែ ដែលបានពិនិត្យលទ្ធផល (រយៈពេល 48-72 ម៉ោង) លទ្ធផលពីការធ្វើ តែស្ត ស្បែក និង ឈ្មោះមន្ទីរពេទ្យ ។ បើមិនចង់ធ្វើ តែស្ត ស្បែក ទេ គឺអ្នកអាចឆ្លើយជាសំនួរបាននៅលើក្រដាសពិសេសមួយ ហៅ TB Risk Assessment Questionnaire Certificate of Completion ដែលស្ថិតនៅក្រោមការគ្រប់គ្រងពីបុគ្គលិកពេទ្យណាម្នាក់ ដែលមានសញ្ញាប័ត្រស្របច្បាប់ ។ សំរាប់សំនួរអំពីការថត X-ray សូមទាក់ទងតាមលេខទូរស័ព្ទ 562-997-8307 ។ ប័ណ្ណ ID ត្រូវមានដូចជា: ប័ណ្ណបើកបរ និង ប័ណ្ណសំគាល់ខ្លួនសំរាប់ប្រើក្នុងរដ្ឋ កាលីហ្វ័រញ៉ា ដែលមិនទាន់ហួស ថ្ងៃ/ខែ ឬ ប័ណ្ណទាហាន ឬ លិខិតឆ្លងដែន ។ **(រូបថត ត្រូវមានគុណភាពបង្ហាញមុខច្បាស់)**

→ អ្នកសុំស្ម័គ្រធ្វើជាគ្រូបង្ហាត់កីឡា និង មុខងារជំរើសផ្សេងៗ គឺត្រូវបង្ហាញភស្តុតាងធ្លាប់បានទទួលការត្រួតត្រាពីមុនមក ឬ ទៅធ្វើការផ្តិតមេដៃជាមួយក្រសួង DOJ និង FBI មុននឹងអាចទទួលមុខងារពីក្រសួងអប់រំ ឌីស្ទ្រីគ បាន ។

→ **Senate Bill 791— ការតំរូវចាក់ថ្នាំសំរាប់មនុស្សធំ ដែលធ្វើកិច្ចការមើលក្មេង**: អ្នកសុំស្ម័គ្រទាំងអស់ ដែលធ្វើការជាមួយក្មេងព្រីស្កូល គឺត្រូវបង្ហាញភស្តុតាងចាក់ថ្នាំរោគ កញ្រ្ជឹល ក្អកមាន់ និង * **គ្រុនផ្តាសាយធ្ងន់** ។ **(*ការចាក់ថ្នាំបង្ការប្រចាំឆ្នាំសំរាប់គ្រុនផ្តាសាយធ្ងន គឺប្រហែលជាអាចទទួលស្គាល់បាន)**

↓

អ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀននឹងសើរើមើលក្រដាសដាក់ពាក្យបំពេញពីអ្នក និង បើធ្វើបានត្រឹមត្រូវហើយ គឺគេសុំឲ្យនាយកសាលាចុះហត្ថលេខានៅពីលើ ។ បន្ទាប់ទៅ គេនឹងផ្ញើក្រដាសដាក់ពាក្យនោះទៅកាន់ការិយាល័យ VIPS នៅតាមក្រសួងអប់រំ ឌីស្ទ្រីគ ។

↓

ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឌីស្ទ្រីគ នឹងត្រូវធ្វើការតាមដានបញ្ជាក់ដោយបើកមើលពត៌មានផ្សេងៗនៅក្នុង វិបសៃ នៃ Megan's Law ។

↓

អ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀនរបស់អ្នកនឹងទទួលដំណឹងមកវិញបន្ទាប់ពីមានការតាមដានបញ្ជាក់ផុតទៅ រួមទាំងប័ណ្ណ VIPS ID របស់អ្នកផង ។ បន្ទាប់ទៅ គេនឹងទាក់ទងប្រាប់អ្នក ។

↓

ឥឡូវ អ្នកអាចចាប់ផ្តើមការស្ម័គ្រជួយសាលារៀនបាន ។ ដើម្បីការពារសិស្ស និង រក្សាភាពសន្តិសុខទូទៅនៅក្នុងសាលារៀន គឺអ្នក**ត្រូវ**សរសេរឈ្មោះរៀងរាល់ពេល ដែលអ្នកបានចូលសាលារៀន និង ចេញពីសាលារៀន ហើយអ្នក**ត្រូវ**ពាក់ ប័ណ្ណ VIPS ID របស់អ្នកភ្ជាប់ខ្លួនជានិច្ច ។ **ហាម**មិនឲ្យយកប័ណ្ណ VIPS ID ចេញពីសាលារៀន (លើកលែងតែពេលធ្វើដំណើរឆ្ងាយពីសាលារៀន) ឬ បណ្តោយឲ្យមនុស្សណាផ្សេងខ្ចីពាក់ប្រើ ។

**សូមអរគុណចំពោះពេលវេលា និង ការបញ្ចេញសមត្ថភាពពីអ្នក!**

សំរាប់សំនួរអំពីរបៀបសុំស្ម័គ្រជួយសាលារៀន សូមទាក់ទង (562) 997-8457 ។
សំរាប់សំនួរអំពីផ្លូវច្បាប់ផ្សេងៗ សូមទាក់ទង (562) 997-8307 ។

Revised: 08-19-17